**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈស្ថាបត្យករកម្ពុជា**
**អគ្គលេខាធិការដ្ឋាន គ.ស.ក.**
លេខ.០០៥......អ.គសក/ស.រ

# សេចក្តីសម្រេច
# ស្តីពី
# នីតិវិធីក្នុងការចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជា

## អគ្គលេខាធិការគណៈស្ថាបត្យករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១១១អនក្រ.បក ចុះថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានឃើញប្រកាសលេខ១៥៦ប្រក.គសក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនៃអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់គណៈស្ថាបត្យករកម្ពុជា
- យោងតាមសំណើរបស់ផ្នែកចុះបញ្ជី និងគុណវុឌ្ឍិនៃអគ្គលេខាធិការដ្ឋានគណៈស្ថាបត្យករកម្ពុជា

## សម្រេច

**ប្រការ ១.-**

ជនទាំងឡាយណាដែលមានបំណងចូលជាសមាជិកគណៈស្ថាបត្យករកម្ពុជា ត្រូវមកសុំបំពេញបែបបទនិងចុះឈ្មោះក្នុងបញ្ជី គ.ស.ក. ស្របតាមលក្ខខណ្ឌដែលបានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការបង្កើត គណៈស្ថាបត្យករកម្ពុជានិងសេចក្តីសម្រេចលេខ០០៣ស.ស.រចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី លក្ខខណ្ឌចុះបញ្ជីនិងការកំណត់ប្រាក់ភាគទាននៃគណៈស្ថាបត្យករកម្ពុជា។

**ប្រការ ២.-**

ដើម្បីបំពេញបែបបទសុំចុះឈ្មោះក្នុងបញ្ជីគ.ស.ក.បេក្ខជនត្រូវបំពេញសំណុំឯកសាររួមមាន៖

- ពាក្យសុំ ដែលផ្តល់ដោយផ្នែកចុះបញ្ជី និងគុណវុឌ្ឍិនៃអគ្គលេខាធិការដ្ឋានគ.ស.ក. ចំនួន០៣ច្បាប់
- ច្បាប់ថតចម្លងដែលមានធ្វើនីត្យានុកូលកម្មនៅសាលារាជធានី ខេត្ត សញ្ញាបត្រស្ថាបត្យកម្ម ឬសញ្ញាបត្រប្រហាក់ប្រហែលដែលមានការទទួលស្គាល់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា របស់បេក្ខជន ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងសម្រង់ពិន្ទុលម្អិតដែលចេញដោយគ្រឹះស្ថានឧត្តមសិក្សា (ប្រសិនបើមាន) ចំនួន០១ច្បាប់
- លិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ពីសាលាឃុំ សង្កាត់ ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ចំនួន០៣ច្បាប់
- បង្កាន់ដៃបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះដែលចេញដោយផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ ចំនួន០១ច្បាប់
- រូបថតរបស់បេក្ខជនទំហំ ៤x៦ (ផ្ទៃក្រោយពណ៌ស) ចំនួន០៥សន្លឹក

បេក្ខជនត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជី គ.ស.ក. នៅអគ្គលេខាធិការដ្ឋានគ.ស.ក.។ ការពិនិត្យនិងការសម្រេចក្នុងការស្នើសុំចុះឈ្មោះក្នុងបញ្ជី គ.ស.ក. មានរយៈពេលយ៉ាងយូរ១៤ (ដប់បួន) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យសុំ ។ បេក្ខជននឹងទទួលបានឋានៈជាស្ថាបត្យករចុះបញ្ជី បន្ទាប់ពីបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១ នៃសេចក្តីសម្រេច លេខ០០៣ស.ស.រចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីលក្ខខណ្ឌចុះបញ្ជីនិងការកំណត់ប្រាក់ភាគទាននៃគណៈស្ថាបត្យករកម្ពុជា។

**ប្រការ ៣.-**

ដើម្បីក្លាយជាស្ថាបត្យករគ.ស.ក. ស្ថាបត្យករចុះបញ្ជីត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក. មានវិញ្ញាបនបត្រស្ថាបត្យករចុះបញ្ជី។

ខ. ប្រវត្តិការងារចាប់ពីថ្ងៃបញ្ចប់ការសិក្សាជំនាញស្ថាបត្យកម្មឬជំនាញប្រហាក់ប្រហែល ដោយជោគជ័យ រហូតដល់ពេលបច្ចុប្បន្ន។

គ. មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិចៈ

- ថ្នាក់បណ្ឌិត — ចំនួន០១ឆ្នាំ
- ថ្នាក់អនុបណ្ឌិត — ចំនួន០២ឆ្នាំ
- ថ្នាក់ស្ថាបត្យករ ឬបរិញ្ញាបត្រស្ថាបត្យកម្ម ឬវិញ្ញាបនបត្រប្រហាក់ប្រហែល — ចំនួន០៣ឆ្នាំ

ឃ. របាយការណ៍ស្តីពីបទពិសោធន៍ការងារជំនាញ និងស្នាដៃការងារកន្លងមក។

ង. ឆ្លងកាត់ការប្រឡងសមត្ថភាពជំនាញវិជ្ជាជីវៈនិងការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃគុណវុឌ្ឍិវិជ្ជាជីវៈស្ថាបត្យកម្ម។

សំណុំឯកសារត្រូវបំពេញរួមមាន៖

- ពាក្យសុំដែលផ្តល់ដោយផ្នែកចុះបញ្ជី និងគុណវុឌ្ឍិនៃអគ្គលេខាធិការដ្ឋានគ.ស.ក. — ចំនួន០៣ច្បាប់
- ច្បាប់ថតចម្លងវិញ្ញាបនបត្រស្ថាបត្យករចុះបញ្ជីរបស់បេក្ខជនដែលមានធ្វើនីត្យានុកូលកម្មនៅសាលារាជធានី ខេត្ត — ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងសម្រង់ពិន្ទុលម្អិតដែលចេញដោយគ្រឹះស្ថានឧត្តមសិក្សា (ប្រសិនបើមាន) — ចំនួន០១ច្បាប់
- លិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ពីសាលាឃុំ សង្កាត់ — ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ — ចំនួន០៣ច្បាប់
- បង្កាន់ដៃបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះជាស្ថាបត្យករគ.ស.ក. ដែលចេញដោយផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ — ចំនួន០១ច្បាប់
- បង្កាន់ដៃបង់ប្រាក់ភាគទានសមាជិកភាពប្រចាំឆ្នាំចុងក្រោយដែលចេញដោយផ្នែករដ្ឋបាល បុគ្គលិកផែនការ និងហិរញ្ញវត្ថុ — ចំនួន០១ច្បាប់
- រូបថតរបស់បេក្ខជនទំហំ៤x៦ (ផ្ទៃក្រោយពណ៌ស) — ចំនួន០៥សន្លឹក

បេក្ខជនត្រូវដាក់ពាក្យសុំនៅអគ្គលេខាធិការដ្ឋានគ.ស.ក.។ បេក្ខជននឹងទទួលបានឋានៈជាស្ថាបត្យករគ.ស.ក. បន្ទាប់ពីបានបំពេញលក្ខខណ្ឌនិងទទួលបានជោគជ័យតាមការវាយតម្លៃលើសមត្ថភាពនិងបទពិសោធការងារ ។

ការពិនិត្យនិងការសម្រេចក្នុងការស្នើសុំជាស្ថាបត្យករគ.ស.ក. មានរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ ៤.-**

ស្ថាបត្យករបរទេសទាំងឡាយដែលបាននិងកំពុង ឬមានបំណងប្រកបវិជ្ជាជីវៈផ្នែកស្ថាបត្យកម្ម ឬផ្នែកប្រហាក់ប្រហែលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវសុំបំពេញបែបបទនិងចុះឈ្មោះក្នុងបញ្ជីគណៈស្ថាបត្យករកម្ពុជា ។

ដើម្បីដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជី គ.ស.ក. បេក្ខជនត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

ក- មានសញ្ញាប័ត្រស្ថាបត្យកម្ម ឬសញ្ញាបត្រប្រហាក់ប្រហែល ដែលមានការបញ្ជាក់ពីស្ថានទូត ឬស្ថានកុងស៊ុលសាមីប្រទេស។

ខ- មានវត្តមានស្នាក់នៅព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច ៣ (បី) ខែ។

សំណុំឯកសារត្រូវបំពេញរួមមានៈ

- ច្បាប់ថតចម្លងសញ្ញាបត្ររបស់បេក្ខជនដែលមានការបញ្ជាក់ពីស្ថានទូតឬស្ថានកុងស៊ុលរបស់សាមីជន — ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីប្រកបវិជ្ជាជីវៈស្ថាបត្យកម្មឬវិជ្ជាជីវៈប្រហាក់ប្រហែលដែលមានការបញ្ជាក់ពីស្ថានទូតឬស្ថានកុងស៊ុលរបស់សាមីជន(ប្រសិនបើមាន) — ចំនួន០១ច្បាប់
- លិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ពីសាលាឃុំ សង្កាត់ — ចំនួន០១ច្បាប់
- ច្បាប់ថតចម្លងលិខិតឆ្លងដែន — ចំនួន០៣ច្បាប់
- បង្កាន់ដៃបង់ប្រាក់ភាគទានសិទ្ធិចុះឈ្មោះដែលចេញដោយផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ — ចំនួន០១ច្បាប់
- រូបថតរបស់បេក្ខជនទំហំ ៤x ៦ (ផ្ទៃក្រោយពណ៌ស) — ចំនួន០៥សន្លឹក

បេក្ខជនត្រូវដាក់ពាក្យសុំនៅអគ្គលេខាធិការដ្ឋានគ.ស.ក.។ បេក្ខជននឹងទទួលបានឋានៈជាស្ថាបត្យករបរទេសចុះបញ្ជី បន្ទាប់ពីបេក្ខជនបានបំពេញលក្ខខណ្ឌដូចក្នុងប្រការ ១នៃសេចក្តីសម្រេច លេខ០០៣ ស.ស.រចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ស្តីពីលក្ខខណ្ឌចុះបញ្ជី និងការកំណត់ប្រាក់ភាគទាននៃគណៈស្ថាបត្យករកម្ពុជា និងត្រូវបានអនុញ្ញាតដោយគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃគុណវុឌ្ឍិវិជ្ជាជីវៈស្ថាបត្យកម្ម ។

ការពិនិត្យនិងការសម្រេចក្នុងការស្នើសុំចុះបញ្ជីជាស្ថាបត្យករបរទេសចុះបញ្ជីមានរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យសុំ។

សុពលភាពនៃវិញ្ញាបនបត្រស្ថាបត្យករបរទេសចុះបញ្ជីមានរយៈពេល០២(ពីរ)ឆ្នាំ ។ រយៈពេល៣០ (សាមសិប) ថ្ងៃមុនផុតកំណត់សុពលភាព ស្ថាបត្យករបទេសចុះបញ្ជីត្រូវមកដាក់ពាក្យសុំបន្តសុពលភាពនៅអគ្គលេខាធិការដ្ឋាន គ.ស.ក.។

**ប្រការ ៥.-**

គណៈស្ថាបត្យករកម្ពុជានឹងដកហូតវិញ្ញាបនបត្ររបស់ស្ថាបត្យករដែលជាសមាជិកគ.ស.ក. ក្នុងករណីដូចខាងក្រោមៈ

- មានការហាមឃាត់ការប្រកបវិជ្ជាជីវៈដោយតុលាការ
- មានសេចក្តីសម្រេចលុបឈ្មោះចេញពីបញ្ជីគ.ស.ក. របស់ក្រុមប្រឹក្សា គ.ស.ក.។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៤

**អគ្គលេខាធិការ**

គ.ស.ក

**គឿន_សុគ៌ណ្ណ**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា
- គ្រប់ផ្នែកនៃអគ្គលេខាធិការដ្ឋានគ.ស.ក.
- ឯកសារ-កាលប្បវត្តិ